## កិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-ជប៉ុន

## ភ្នំពេញ, ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០២២

## សុន្ទរកថាបើក

## សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា

**ឯកឧត្តម ណូប៊ូអូ គីហ្ស៊ី (Nobuo Kishi) រដ្ឋមន្ត្រីកាពារជាតិជប៉ុន!**
**ឯកឧត្តមរដ្ឋមន្ត្រីការពារជាតិអាស៊ានទាំងអស់!**
**អស់លោក លោកស្រី!**

ជាកិច្ចចាប់ផ្តើម ក្នុងនាមក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមស្វាគមន៍ចំពោះ **ឯកឧត្តម ណូប៊ូអូ គីហ្ស៊ី (Nobuo Kishi) រដ្ឋមន្ត្រីការពារជាតិជប៉ុន** និងឯកឧត្តមរដ្ឋមន្ត្រីការពារជាតិអាស៊ានទាំងអស់ ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-ជប៉ុននាពេលនេះ ដែលធ្វើឡើងនៅក្នុងទម្រង់រូបវន្ត។ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយ ចំពោះការផ្តល់កិត្តិយស និងបង្ហាញពីការជឿទុកចិត្តលើរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ត្រឹមត្រូវប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានខិតខំក្នុងការទប់ស្កាត់ជំងឺកូវីដ-១៩ ទទួលបានលទ្ធផលគួរឱ្យស្ញប់ស្ញែង និងដែលបានអនុញ្ញាតឱ្យកិច្ចប្រជុំទាំងឡាយ អាចដំណើរការទៅបាននៅក្នុងទម្រង់រូបវន្តនាពេលនេះ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី!**

**ខ្ញុំសូមធ្វើការចែករំលែកនូវទស្សនៈរបស់ខ្ញុំទាក់ទិននឹងបញ្ហាសន្តិសុខ ដូចខាងក្រោម ដោយផ្តោតទៅលើបញ្ហាពីរៈ**

ពិភពលោករបស់យើងត្រូវបានរំខានដោយជំងឺកូវីដ-១៩ អូសបន្លាយអស់រយៈពេលប្រមាណជាង២ឆ្នាំមកហើយ ដែលជំងឺនេះបានបង្កឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់វិស័យសេដ្ឋកិច្ចសកល នាំមកនូវគម្លាតអភិវឌ្ឍន៍កាន់តែធំ រវាងប្រទេសក្រីក្រ និងប្រទេសអភិវឌ្ឍន៍។ យ៉ាងណាមិញ ស្ថានភាពជំងឺកូវីដ-១៩ នាពេលបច្ចុប្បន្ន គឺបានថមថយមួយកម្រិតគួរឱ្យកត់សម្គាល់ ក៏ប៉ុន្តែការគំរាមកំហែងគឺនៅតែបន្តមាន ខណៈពិភពលោកទាំងមូលមិនទាន់ទទួលបានភាពស៊ាំជាសហគមន៍នៅឡើយ។ ទាក់ទិននឹងបញ្ហានេះ កម្ពុជាគឺពិតជាមានមោទនភាពក្រៃលែង ដែលកម្ពុជាមិនមានអ្នកឆ្លងជំងឺកូវីដ-១៩ អស់រយៈពេល៣៦ថ្ងៃជាប់គ្នា ខណៈយុទ្ធនាការចាក់វ៉ាក់សាំងទូទាំងប្រទេស ក៏ទទួលបានឈានដល់ការចាក់នូវ ដូសទី៥ ដល់ប្រជាពលរដ្ឋកម្ពុជា។ ជាការពិតណាស់ ការទទួលបាននូវសមិទ្ធផលនេះ គឺដោយសារតែមានការចូលរួមចំណែក និងកិច្ចសហប្រតិបត្តិការពីប្រទេសជាដៃគូក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។ ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលជប៉ុន ដែលបានផ្តល់នូវវ៉ាក់សាំងប្រមាណមួយលានបីសែនដូស តាមរយៈសម្ព័ន្ធវ៉ាក់សាំងកូវ៉ាក់ (COVAX) និងការផ្តល់ហិរញ្ញប្បទានឥតសំណងដល់កម្ពុជាផងដែរ។

ជាមួយគ្នានេះផងដែរ កម្ពុជាក៏សូមថ្លែងអំណរគុណដល់ប្រទេសជប៉ុន ដែលបានគាំទ្រចំពោះតួនាទីកម្ពុជា ក្នុងនាមជាប្រធានអាស៊ានឆ្នាំ២០២២ ជាពិសេសភាពសកម្មរបស់ជប៉ុន ក្នុងការជួយសម្រួលដល់កម្ពុជាក្នុងការអនុវត្តការព្រមព្រៀងជាឯកច្ឆន្ទ៥ចំណុចក្នុងការដោះស្រាយបញ្ហាវិបត្តិនយោបាយនៅក្នុងប្រទេសមីយ៉ាន់ម៉ា។ ដោយយោងតាមស្មារតីនៃសេចក្តីថ្លែងការណ៍រួម រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសជប៉ុន នៅក្នុងដំណើរទស្សនកិច្ចមកកាន់កម្ពុជា របស់**ឯកឧត្តមនាយករដ្ឋមន្ត្រី គីស៊ីដា ហ្វូមីអូ (KISHIDA Fumio)** កម្ពុជាសូមធ្វើការអំពាវនាវសារជាថ្មី ឱ្យគ្រប់ភាគីទាំងអស់ បញ្ឈប់ជាបន្ទាន់នូវអំពើហិង្សា ធ្វើការអត់ធ្មត់ជាអតិបរមា និងចាប់ផ្តើមដំណើរការចរចារសម្រាប់ដោះស្រាយប្រកប ដោយសន្តិវិធីដើម្បីវិលត្រឡប់ទៅរកប្រក្រតីភាព និងប្រព័ន្ធនយោបាយប្រជាធិបតេយ្យឡើងវិញ។

ដោយសារពេលវេលាមានកំណត់ ខ្ញុំសូមធ្វើការសង្ខេបនូវទស្សនៈរបស់ខ្ញុំ ត្រឹមពីរចំណុចនេះ ហើយខ្ញុំជឿជាក់ថាសមភាគីរដ្ឋមន្ត្រីការពារជាតិអាស៊ាន នឹងមានការស្វែងយល់បន្ថែមទៀតអំពីបញ្ហាប្រឈមនៅក្នុងតំបន់ និងផ្តល់នូវអនុសាសន៍សំខាន់ៗ ដើម្បីចូលរួមចំណែកដល់ការលើកកម្ពស់កិច្ចសហប្រតិបត្តិការអាស៊ាន-ជប៉ុន បន្ថែមទៀត។ **ដូច្នេះជាកិច្ចបន្ទាប់ ខ្ញុំសូមអញ្ជើញឯកឧត្តមរដ្ឋមន្ត្រីការពារជាតិជប៉ុន ណូប៊ូអូ គីហ្ស៊ី មានមតិ។**

**ឯកឧត្តម ណូប៊ូអូ គីហ្ស៊ី (Nobuo Kishi) រដ្ឋមន្ត្រីកាពារជាតិជប៉ុន!**

**ឯកឧត្តមរដ្ឋមន្ត្រីការពារជាតិអាស៊ានទាំងអស់!**

**អស់លោក លោកស្រី អ្នកនាងកញ្ញា!**

ជាថ្មីម្តងទៀត តាងនាមក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណចំពោះ**ឯកឧត្តម ណូប៊ូអូ គីស៊ី រដ្ឋមន្ត្រីការពារជាតិជប៉ុន** និងឯកឧត្តមរដ្ឋមន្ត្រីការពារជាតិអាស៊ានទាំងអស់ ដែលបានចំណាយពេលវេលានិងការប្រឹងប្រែង ធ្វើឲ្យកិច្ចប្រជុំកិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-ជប៉ុន សម្រេចបាននូវលទ្ធផលប្រកបដោយផ្លែផ្កា និងឈរលើស្មារតីមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការ។ មុននឹងបញ្ចប់ ខ្ញុំសូមធ្វើការសង្ខេបនូវសមិទ្ធផល ដែលយើងទទួលបាននៅក្នុងកិច្ចប្រជុំថ្ងៃនេះ។

នៅក្នុងកិច្ចពិភាក្សានិងការចែករំលែកនូវទស្សនៈស្តីពីបញ្ហាសន្តិសុខ អង្គប្រជុំបានលើកឡើងអំពីបញ្ហាប្រឈមជាសកល និងតំបន់ដែលបាននឹងកំពុងបង្កការគំរាមកំហែងដល់សន្តិភាព និងសន្តិសុខ ដូចជាបញ្ហាជំងឺកូវីដ-១៩ បញ្ហាសន្តិសុខប្រពៃណី និងមិនប្រពៃណី។ រដ្ឋមន្ត្រីការពារជាតិអាស៊ាន-ជប៉ុន បានឯកភាពគ្នាលើសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការ និងការជំរុញឱ្យមានកិច្ចសហប្រតិបត្តិការបន្ថែម ជាពិសេសកិច្ចសហប្រតិបត្តិការក្រោយពីជំងឺកូវីដ-១៩។ ជាមួយគ្នានេះ រដ្ឋមន្ត្រីការពារជាតិអាស៊ាន ក៏បានស្វាគមន៍ចំពោះគំនិតផ្តួចផ្តើមស្តីពី **"ទស្សនវិស័យទីក្រុងវៀងចន្ទ ២.0"** របស់ជប៉ុន ដែលជាឧបករណ៍ដ៏សំខាន់ក្នុងការតម្រង់ទិសដៅ និងលើកម្ពស់កិច្ចសហប្រតិបត្តិការការពារជាតិអាស៊ាន-ជប៉ុន ដោយផ្អែកលើគោល រណ៍មជ្ឈភាព និងតួនាទីនាំមុខរបស់អាស៊ាន។ យោងតាមសមិទ្ធផលនៃ **ទស្សនវិស័យទីក្រុងវៀងចន្ទឆ្នាំ២០១៦** កម្ពុជាជឿជាក់ថា **ទស្សន វិស័យទីក្រុងវៀងចន្ទ ២.0** នឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការអាស៊ាន-ជប៉ុន និងបង្កើតបានជាកិច្ចសហប្រតិបត្តិការជាក់ស្តែងបន្ថែមទៀត ក្នុងការរួមគ្នាដោះស្រាយបញ្ហាសន្តិសុខនាពេលបច្ចុប្បន្ន និងអនាគត និងបន្តជាចលករដ៏សំខាន់ក្នុងការនាំមកនូវសន្តិភាព ស្ថិរភាព និងសន្តិសុខតំបន់។ ឆ្លៀតឱកាសនេះ ខ្ញុំក៏សូមឱ្យប្រទេសជប៉ុន បន្តជួយលើការពង្រឹងសមត្ថភាពធនធានមនុស្សលើជំនាញសំខាន់ៗ ដល់បណ្តាកងទ័ពអាស៊ាន ដើម្បីការចូលរួមចំណែកដល់ការពង្រឹង និងថែរក្សាសន្តិភាពនៅក្នុងតំបន់។

ជាទីបញ្ចប់ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចប្រជុំនាថ្ងៃនេះ និងសូមអរគុណដល់រដ្ឋមន្ត្រីការពារជាតិជប៉ុន និងរដ្ឋមន្ត្រីការពារជាតិអាស៊ាន ដែលបានចំណាយពេលវាដ៏មានតម្លៃ ចូលរួមចំណែកក្នុងការធ្វើឱ្យកិច្ចប្រជុំនេះទទួលបានជោគជ័យ។ ពិភពលោករបស់យើងបានប្រឈមនឹងបញ្ហាស្មុគស្មាញជាច្រើននៅក្នុង រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលទាមទារឱ្យមានការជួបពិភាក្សាគ្នានិងពង្រឹងកិច្ចសហប្រតិបត្តិការកាន់តែខ្លាំង ដើម្បីកាត់បន្ថយហានិភ័យនានា លុបបំបាត់ការយល់ច្រឡំផ្សេងៗ កសាងទំនុកចិត្តបន្ថែម រួមគ្នាស្តារប្រទេសជាតិឡើងវិញក្រោយពីវិបត្តិជំងឺកូវីដ-១៩ និងកសាងភាពធន់របស់អាស៊ានដើម្បីប្រឈមនឹងបញ្ហាផ្សេងៗ។ កម្ពុជា មានជំនឿយ៉ាងមុតមាំថា កិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-ជប៉ុន និងកិច្ចសហប្រតិបត្តិការការពារជាតិអាស៊ាន-ជប៉ុនជារួម ផ្អែកលើ**ទស្សនវិស័យទីក្រុងវៀងចន្ទ ២.០** នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចបានគោលបំណងទាំងនេះ និងជំរុញឱ្យកិច្ចសហប្រតិបត្តិការ អាស៊ាន-ជប៉ុនមានការអភិវឌ្ឍរីកចម្រើនតទៅមុខទៀត និងក្លាយជាផលប្រយោជន៍ដល់ប្រជាជននៃអាស៊ាន-ជប៉ុន ដើម្បីលើកកម្ពស់សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍនៅក្នុងតំបន់ និងពិភពលោក។

ខ្ញុំសូមប្រកាសបិទកិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-ជប៉ុន នៅពេលនេះ។

**សូមអរគុណ!**